# បងអប់រំខ្មី

## ស្តីអំពី: ជំនឿ និងទស្សនៈ(មិនទំនង)

មុននឹងបកស្រាយទៅលើជំនឿនិងទស្សនៈ(មិនទំនង) នៅកម្ពុជានោះ ខ្ញុំសូម ជម្រាបជូននូវទស្សនវិជ្ជាពុទ្ធសាសនា យ៉ាងខ្លីសម្រាប់ការពិចារណាទាំងអស់គ្នា ។ នេះជាចំណុច ១ក្នុងចំណុចយ៉ាងច្រើននៃទស្សនវិជ្ជាពុទ្ធសាសនា គឺ**សទ្ធា**។ សទ្ធាក្នុងទីនេះសំដៅដល់ជំនឿ ដែលប្រកបដោយបញ្ញា ពិចារណាឃើញដឹង ច្បាស់នូវកិច្ចការណាមួយដែលបុគ្គល ត្រូវធ្វើជាកម្លាំង(**សទ្ធាពល**)។ បុគ្គលដែលធ្វើការអ្វីមួយ ហើយមិនបានសម្រេចតាមសេចក្តីប្រាថ្នា មិនមែនខ្វះអ្វី មួយនោះទេ ពោលគឺខ្វះនូវធម៌ពីរប្រការ សទ្ធា និងបញ្ញា។

ព្រះបរមពោធិសត្វ ដែលបានសម្រេចភាពនៃ ព្រះពុទ្ធក៏ដោយសារសទ្ធាប្រកបដោយបញ្ញា ចាប់តាំងពី

ទ្រង់តាំងព្រះទ័យសាងបារមីឲ្យសម្រេចអនុត្តរធម៌ និង សម្មាសម្ពោធិញ្ញាណ សទ្ធានេះហៅថា **អាគមសទ្ធា**។

ព្រះអរហន្តគ្រប់អង្គក៏មានសទ្ធាប្រកបដោយបញ្ញា ទើបបានប្រចក្សនូវធម៌ ដែលព្រះតថាគតត្រាស់ទុកហើយ សទ្ធានេះហៅថា**អធិគមសទ្ធា** ។ ចំណែកការជឿជាក់ច្បាស់ មិនកម្រើកចំពោះគុណព្រះរតនត្រ័យក៏ដោយសទ្ធាដែល ប្រកបដោយបញ្ញា សទ្ធានេះហៅថា**ឱកប្បកសទ្ធា**។

ចិត្តដែលប្រាថ្នាចំពោះអំពើកុសល ដោយបានយក បញ្ញាមកពិចារណាឲ្យ ឃើញពិត ដឹងពិត យល់ពិត ថាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ សទ្ធានេះហៅថា **បសាទសទ្ធា**។

ដោយខ្ញុំនិយាយពីព្រឹត្តិការណ៍ ដែលបានកើត ឡើងនៅស្រុកខ្មែរវិញ តាមដែលខ្ញុំបានជួបផ្ទាល់និងដឹង មិនតិចជាង១០ករណីទេ ហើយតាមការអង្កេតទៅលើ ករណីដែលបានកើតឡើងហើយនោះ សុទ្ធតែជារឿង ដែលមិនពិតនិងមិន អាចយកជាគតិបានទាំងអស់សម្រាប់ សង្គមខ្មែររាប់អានព្រះពុទ្ធសាសនា។

ឥឡូវសូមប្រិយមិត្តអ្នកអានទាំងឡាយតាមដាននូវរឿងខ្លះៗជាមួយនឹងខ្ញុំ ដូចខាងក្រោម៖

**ជំនឿហូបបបរសណ្តែក:** អំឡុងឆ្នាំ២០០៣ ព្រឹត្តិការណ៍នេះបានកើតឡើង ស្ទើរទូទាំងផ្ទៃប្រទេសខ្មែរដោយមានអ្នកឃោសនាតៗគ្នា ថាបើអ្នកណាមួយមិនបរិភោគបបរសណ្តែកឲ្យបានមុនម៉ោង១២រំលោងអធ្រាត្រទេ អ្នកនោះនឹងស្លាប់ដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់ ។



សម្រាប់ខ្ញុំ នៅចាំបានថាពេលនោះ ខ្ញុំកំពុងស្នាក់នៅវត្ត វេឡុវែនព្រៃឬស្សី ខេត្តកណ្តាល បច្ចុប្បន្នជារាជធានីភ្នំពេញ អ្វីដែលខ្ញុំចាំបានយ៉ាងច្បាស់មិនភ្លេចនោះ គឺមិនមែនត្រឹមតែអ្នកស្រុកអ្នកភូមិប៉ុណ្ណឹងទេដែល ជ្រួលជ្រើលភ័យស្ទន់ស្ទោខ្លាចស្លាប់ សូម្បីតែអ្នកបួសនិងតាជីដូនជីមួយចំនួនក៏មានទំនងដូចអ្នកស្រុកអ្នកភូមិអ៊ីចឹងដែរ ថែម

ទាំងលោកយាយខ្លះភ័យខ្លាចលោកសុគតពេក ក៏បាន បបរសណ្តែក ឲ្យលោកឆាន់ទាំងយប់មានលោកខ្លះឆាន់ លោកខ្លះមិនឆាន់ ហើយសម្រាប់អ្នកស្រុកវិញជាស់កូន ជាស់ចៅជាស់ប្តីជាស់ប្រពន្ធឲ្យភ្ញាក់ឡើងដើម្បីពិសាបបរ សណ្តែកក្រែងមិនបានរស់នឹងគេ ហើយមានកន្លែងខ្លះទៀត បបរមិនឆ្អិនបានត្រឹមតែលាយទឹកនិងសណ្តែក ហើយនាំគ្នា ពិសាដោយពុំបានចម្អិនឲ្យបានត្រឹមត្រូវ ក៏បណ្តាលឲ្យមាន រាករូសច្រើនគ្នាផងដែរ ប៉ុណ្ណឹងហើយក៏ពួកគាត់គិតថា សំណាងដែរ ដែលបានផឹកទាន់ពេលវេលាកុំអីប្រហែលជា ស្លាប់ ក៏ថាបាន។

ពុទ្ធោអើយ! រឿងពិតដែលបានបំភ្លឺក្រោយព្រឹត្តិ-ការណ៍នេះត្រូវបានបញ្ចប់ គឺវាជារឿងដែលគួរឲ្យខ្មាសគេ ជាពិសេសពួកបរទេសដែលគេបានដឹង ព្រោះខ្មែរជាអ្នក បានទទួលការគោរពពុទ្ធសាសនាជាយូរមកហើយផង មិន គួរណាមានការជឿមិនទំនងក្នុងរឿងអ៊ីចឹងសោះ ។ តាមពិត សណ្តែកលក់មិនដាច់នៅក្នុងឃ្លាំងច្រើនពេក អ្នកលក់ក៏ បានសហការជាមួយហោរ ដើម្បីរកគន្លឹះធ្វើយ៉ាងណាឲ្យ

សណ្តោកលក់ចេញបាន ហើយក្រោយពីបានសហការជាមួយគ្នា ហើយកិច្ចការនេះក៏បានជោគជ័យទាំងស្រុងដែលមិនអាចប្រកែកបាន គឺសណ្តោកត្រូវបានអស់ពីឃ្លាំងការចំណោញ គឺបានកប់ក្តោងរបស់ពួកឈ្មួញ ។

**ជំនឿសត្វជ្រូកព្រៃជាអ្នកមានបុណ្យ:** អំឡុងឆ្នាំ២០០៥ រឿងនេះបានកើតឡើងនៅភូមិត្បែង ឃុំបុស្សូរ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ ពេលមួយសត្វជ្រូកព្រៃមួយក្បាលបានរត់ចូលក្នុងភូមិខាងលើបណ្តាលឲ្យអ្នកភូមិនេះ និងភូមិដទៃបានគិតថាជ្រូកព្រៃនេះមានអ្នក



មានបុណ្យចូលមកសណ្ឋិត បន្ទាប់មកទៀតក៏នាំគ្នាថ្វាយ

បង្គំអុជធូបបន់ស្រន់និងលាបប្រេងម្សៅផ្ទូតទឹកឲ្យដល់សត្វជ្រូក ហើយត្រូវយកនូវទឹកនោះមកផឹកនិងផ្ងូតគ្រប់គ្នាៗ ហើយរឿងដែលគិតស្មានមិនដល់នោះគឺមនុស្សដែលមានជំនឿទាំងអស់នោះបានដកនូវរោមសត្វចែកគ្នាម្នាក់មួយៗ រហូតទាល់តែសត្វទ្រាំពុំបានក៏រត់ចូលព្រៃវិញទៅ។

រឿងពិតដែលបានកើតឡើងក្នុងព្រឹត្តិការណ៍នេះ គឺមិនពិបាកយល់ទេ វាគ្រាន់តែមនុស្សយើងបានយល់ខុស ហើយរៀបចំឡើងតែប៉ុណ្ណោះ ព្រោះថាតាមពិតដោយសារតែមនុស្សកាប់ព្រៃឈើស្ទុកៗអស់ទៅ សត្វជ្រូកព្រៃមួយក្បាលនេះ ក៏មិនមានទីជម្រកដូចមុនក៏ចេះតែដើរទៅរត់ទៅ រហូតបានមកដល់ចំណុចភូមិខាងលើនេះ ហើយវាគ្មានអ្នកមានបុណ្យណាមកសណ្ឋិតក្នុងខ្លួនរបស់សត្វព្រូកព្រៃនេះឡើយ។

**ជំនឿដើមស្នួលដួលហើយងើបឡើងវិញ:** នៅភូមិសំរោងធំ ឃុំឈ្នួរមានជ័យ ខេត្តបន្ទាយមានជ័យ ចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៤នេះមក អ្នកភូមិជាច្រើនបានពពាក់ពពូនគ្នាទៅ ថ្វាយបង្គំដើមឈើនេះ អុជធូបបន់ស្រន់

សុំលេខឆ្នោតពីដើមឈើឈ្មោះស្នួល ដែលដួលហើយស្រាប់តែងើបឡើងវិញ ដោយមានជំនឿថាដើមឈើនេះ



នឹងផ្តល់សេចក្តីសុខ សេចក្តីចម្រើនឲ្យដល់ពួកគាត់ ។ គ្រាន់តែឮថា មានរឿងនេះកើតឡើងភ្លាមខ្ញុំបាននឹកដល់រឿងគតិលោកមួយដែលបាននិទានមកថា មានដើមដង្កោមួយដើម ដួលរលំនៅកណ្តាលវាល ។ អ្នកស្រុកអ្នកភូមិដែលដើរទៅមកតែងតែឃើញដើមដង្កោនេះដួលរលំដូច្នេះឯង ។ លុះរយៈកាលយូរថ្ងៃក្រោយមក មានក្មេងគង្វាលគោម្នាក់

បានយកពូថៅទៅកាប់លះមែកដង្កោនោះចេញ ។ ដើមដង្កោនោះ លុះត្រូវក្មេងកាប់មែកចេញហើយក៏ស្រាលដើមហើយឫសវាក៏ចាប់ទាញដើមឲ្យក្រោកឈរឡើង ។ ពួកអ្នកភូមិ កាលឃើញនូវព្រឹត្តិការណ៍នេះភ្លាម នាំគ្នាផ្អើលឈូឆរដោយឥតដឹងពីមូលហេតុទើបសម្គាល់ថា ដើមដង្កោនេះជារុក្ខជាតិពូកែសក្តិសិទ្ធិទើបបបួលគ្នាយកទៀនធូប ម្ហូបចំណីបារីបូជាសែនព្រេនសុំយកសេចក្តីសុខរហូតមានអ្នកខ្លះទៅស្ទោះយកសំបកស្ងោរផឹក បណ្តាលឲ្យកើតជំងឺរាករូសជាច្រើនគ្រួសារ។ កាលអាជ្ញាធរឃើញហេតុការណ៍ទាំងអស់នេះ ថាមិនត្រូវទំនងទើបចេញសេចក្តីហាមប្រាមចំពោះអ្នកភូមិទាំងអស់នោះ ។

បើតាមរឿងនិទានខ្ញុំខាងលើនេះ ខ្ញុំអាចនិយាយបានថាបណ្តាលមកពីក្រុមខិលខូចលើកឲ្យឈរឡើងវិញនេះមួយ ហើយមួយទៀតអាចមកពីឫសដែលវាទាញឲ្យឈរវិញ ឬអាចបណ្តាលមកពីបាតុភូតធម្មជាតិក៏ថាបាន។

**រឿងជំនឿអ្នកកើតឆ្នាំរកាត្រូវស្រោចទឹក:** នៅថ្ងៃ១៨ ខែឧសភា ឆ្នាំ២០១៤ មានអ្នកជំនឿជ្រុលនិយមពីរបីនាក់ក្នុងភាគខាងជើងនៃខេត្តបន្ទាយមានជ័យ បានដើរបំផុសបំផុល ឲ្យមនុស្សទាំងឡាយណាដែលកើតឆ្នាំរកា ត្រូវតែស្រោចទឹក និងដើរសុំទានគេឲ្យគ្រប់ ៧ ផ្ទះ ទោះបីគេដាក់ក្តី គេមិនដាក់ក្តី ដោយដាច់ខាត ដោយហោចទៅ សូម្បីតែ ព្រះសង្ឃដែលកើតឆ្នាំរកា ក៏ត្រូវតែស្រោចទឹកដែរ ។ អ្នកដើរបំផុសបំផុលនោះបាននិយាយថា




បើអ្នកណាមួយមិនបានស្រោចទឹកទេនឹងត្រូវរន្ទះបាញ់ស្លាប់មិនខាន ។ ប៉ុន្តែសម្រាប់ព្រះសង្ឃ **វត្តប្រាសាទស្រះ-កណ្តាល(ខ្វាស់)** មួយចំនួនក៏មានកើតក្នុងឆ្នាំរកាដែរ ហើយពុំមានអង្គណាមួយត្រូវបានស្រោចទឹកទេ ថាតើនឹងត្រូវរន្ទះបាញ់ដូចគេថាដែរឬទេ។ រឿងមង្គលភ្ញាក់ផ្អើលមានច្រើនទៀតដូចកាលឆ្នាំ២០១០ នៃករណីបញ្ហា

កោះពេជ្រជាដើម ដែលធ្វើឲ្យ មានការសែនព្រេនទូវផ្ទៃចេក បើមិនបានសែនទេនឹងត្រូវ ជួបនូវវិបត្តិភ័យន្តរាយផ្សេងៗ តែខ្ញុំមិនបានសរសេរសព្វ គ្រប់ទាំងអស់ទៅទេ តែយ៉ាងណាក៏ដោយចុះខ្ញុំក៏បាន រៀបរាប់ល្មមស្ដាប់បានហើយចំពោះជំនឿមិនទំនងក្នុងសង្គមខ្មែរ។

ដោយអត្ថបទតម្រូវឲ្យសរសេរខ្លី ខ្ញុំគ្រាន់តែលើករឿងជាឧទាហរណ៍ជាក់ស្ដែងមកជម្រាបជូនប្រិយមិត្តអ្នកអានត្រឹមតែប៉ុណ្ណោះចុះ ដើម្បីបានជាកាពិចារណាទាំងអស់គ្នា៕

ថ្ងៃពុធ ៨រោច ខែពិសាខ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨
ត្រូវនឹងថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៤

**ដោយ ព្រះមហាជម្នាលវណ្ណោ ចាន់ សុជន**